ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ២០១៨

**សេចក្តីផ្តើម :**

នៅក្នុងខែមេសានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:**

**១.មុខងារនីតិកម្ម:**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក សម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ចំនួន០១លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈ<br>- បានបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា<br>- បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និង | - បានអនុវត្តផែនការត្រៀមបើកសម័យប្រជុំដំបូង និងសម័យប្រជុំពេញអង្គលើកទី១ព្រឹទ្ធសភា នីតិកាលទី៤<br>- បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ សម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៤ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា<br>- បានសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗ សរុបចំនួន០៥លើក មានអ្នកចូលរួមចំនួន៤៥១នាក់<br>- ថតចម្លងឯកសារបានចំនួន៦១៣ច្បាប់ អស់ក្រដាសចំនួន៦,២៦១សន្លឹក |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| ពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់។ | - បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន២២លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន១៣២នាក់ ស្មើនឹង០៧លើក<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ពីរដ្ឋសភា ហើយបានចាត់ចែងតាមនីតិវិធី<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន២៨២ច្បាប់<br>- បានសិក្សាស្រាវជ្រាវ និងធ្វើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់<br>- បានរៀបចំទីកន្លែងប្រជុំ ធ្វើលិខិតអញ្ជើញចំនួន០៣លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន១៤លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន០៩លើក ។ |

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចុះសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិជ្រៃធំនៅខេត្តកណ្តាល | - បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤១នាក់ ស្មើនឹង០៨ច្បាប់<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ |

| | |
|---|---|
| + អញ្ជើញចុះតាមដានសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មាន នៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ។ | នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១៩នាក់ ស្មើនឹង០៣លើក<br>- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន០១លើក ។ |

**៣.មុខងារតំណាង :**

| *រចនាសម្ព័ន្ធនយោបាយ* | *រចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញចូលរួមបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញធ្វើសច្ចាប្រណិធាន នៅចំពោះព្រះភក្ត្រព្រះមហាក្សត្រ ព្រះភក្ត្រនៃព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង<br>+ អញ្ជើញទទួលព្រះរាជដំណើរព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះអង្គស្តេចយាងមកដល់មាតុភូមិវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ<br>+ អញ្ជើញជូនព្រះរាជដំណើរព្រះករុណា | - រៀបចំបែបបទ ផ្ដល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន១៨២លើក<br>- បានផ្ដល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការចុះជួបពិភាក្សាការងារ ការចុះតាមដានសិក្សាឈ្វេងយល់អំពីវឌ្ឍនភាព ចែករំលែក និងផ្ដល់ព័ត៌មាន ការចុះតាមដានក្រោយការរៀបចំវេទិកា និងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ស្រះទឹកចំនួន០៣កន្លែង ព្រមទាំងកម្មវិធីផ្សេងៗ នៅខេត្តត្បូងឃ្មុំ កំពត ព្រៃវែង ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង<br>- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា និងក្នុងពិធីផ្សេងៗចំនួន០៧លើក<br>- បានរៀបចំរបាំត្រុដិ របាំជូនពរ កម្មវិធីលេងល្បែងប្រជាប្រិយ ព្រមទាំងរៀបចំពិធីសូត្រមន្ត និងពិធីជប់លៀងអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ |

| | |
|---|---|
| ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គស្តេចយាងពីមាតុប្រទេស ដើម្បីបំពេញព្រះរាជទស្សនកិច្ចនៅព្រះរាជាណាចក្រជប៉ុន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ<br>+ អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខសមាជិកព្រឹទ្ធសភា លោកយាយ លោកតា សិស្ស និស្សិត និងប្រជាពលរដ្ឋ នៅខេត្តកំពង់ចាម និងខេត្តរតនគិរី<br>+ អញ្ជើញនាំយកបច្ច័យ ទេយ្យវត្ថុ គ្រឿងបង្សុកូល គ្រឿងឧបភោគ បរិភោគ និងចង្ហាន់ ទៅប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវមហាឧបាសក **គង់ ខាត់** ព្រមទាំងបុព្វការីជនញាតិការទាំងប្រាំពីរសណ្តាន នៅរាជធានីភ្នំពេញ និងខេត្តកំពង់ចាម<br>+ អញ្ជើញប្រារព្ធ និងចូលរួមពិធីបុណ្យខួបគម្រប់១០០ថ្ងៃ ដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសកគង់ ខាត់ និងបុណ្យអាយុវឌ្ឍនកម្មពូនភ្នំខ្សាច់មហាធាតុ (បុព្វការីជន) ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅវត្តសុវណ្ណគិរី-ជើងធ្នុក ខេត្តកំពង់ចាម<br>+ អញ្ជើញដឹកនាំគណៈប្រតិភូសមាជិកព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធ និងចូលរួមរំលែកទុក្ខក្រុមគ្រួសារសព ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត ឯម **សំអាន** | - បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣០៤នាក់ ស្មើនឹង៧១ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន០៨រូប ស្មើនឹង០៨ច្បាប់<br>- ថតចម្លងឯកសារបានចំនួន១,២៣៣ច្បាប់ អស់ក្រដាសចំនួន១,៩៦២សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្តក្រុង និងរាជធានីភ្នំពេញចំនួន២៤៤នាក់ ស្មើនឹង៧០លើក<br>- បានទទួលលិខិតចូលចំនួន១,២៣៥ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៥៥ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១២៥លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង០៤លើក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០៣លើក<br>- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់<br>- បានរៀបចំអំណោយ៣០កញ្ចប់ ជូនទៅគណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ សម្រាប់ចុះសួរសុខទុក្ខអ្នកជំងឺ និងកុមារកំព្រា |

| | |
|---|---|
| រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងឯកឧត្តម **រ៉ាស៊ីម សំរិទ្ធិ** ទីប្រឹក្សារាជរដ្ឋាភិបាល នៅរាជធានីភ្នំពេញ<br>+ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទការប្រកួតកីឡាបាល់ទាត់ពានរង្វាន់ឯកឧត្តម **នៃ ប៉េណា** អនុប្រធានទី១ព្រឹទ្ធសភា ដែលមានការចូលរួមពីសមាជិករដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល ទីប្រឹក្សា និងថ្នាក់ដឹកនាំជុំវិញខេត្តកំពត នៅពហុកីឡដ្ឋានបាល់ទាត់ខេត្តកំពត<br>+ អញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្តចម្រើនសិរីមង្គល ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២<br>+ អញ្ជើញជប់លៀងជូនគណៈប្រតិភូ ដែលមកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីជីវភាព និងការរស់នៅរបស់ប្រជាពលរដ្ឋរស់នៅតាមតំបន់ភ្នំ នៅខេត្តពោធិ៍សាត់<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន០៥ករណី បញ្ជូនពាក្យបណ្តឹងទៅស្ថាប័នពាក់ព័ន្ធចំនួន០៦ករណី ទទួលលិខិតឆ្លើយតបពាក្យបណ្តឹងចំនួន០២ករណី ព្រមទាំងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន១៣ករណី និងតម្កល់ទុកមិនចាត់ការចំនួន០១ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ ទូទាំងប្រទេសចំនួន៦៥លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល | - បានផ្តល់អត្ថបទ និងរូបថតចំនួន៩២៩សន្លឹក ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៣៧នាក់ ខ្ចីសៀវភៅចំនួន៣២ក្បាល និងសងវិញចំនួន៣៥ក្បាល<br>- បានផ្តល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនដល់សាលាបណ្តុះបណ្តាលនាយទាហាននៅខេត្តបាត់ដំបង និងរដ្ឋសភាចំនួន៣៣០ក្បាល<br>- បានទទួលឯកសារ សៀវភៅ ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងព្រឹត្តិបត្រ ទស្សនាវដ្តី ពីអង្គភាពចំណុះលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៣៧ក្បាល និងកាសែតចំនួន២០១ច្បាប់<br>- បានរៀបចំទស្សនាវដ្តីប្រចាំខែមេសា ឆ្នាំ២០១៨<br>- បានថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន៥៨លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន២៦លើក<br>- បានផ្សព្វផ្សាយវីដេអូស្តីពី ការអភិវឌ្ឍព្រឹទ្ធសភា ១៩ឆ្នាំចំនួន០១លើក ។ |

| | |
|---|---|
| សួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៦លើក។ | |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចប្រធានព្រឹទ្ធសភា បានជួបសម្តែងការគួរសម និងសវនាការជាមួយប្រធាននយោបាយបញ្ជាការដ្ឋានយោធភូមិភាគទី៧ នៃកងទ័ពប្រជាជនវៀតណាម និងគណៈប្រតិភូរដ្ឋសភាវៀតណាម នាយកមូលនិធិខុនវ៉ាដអាដិនណៅអ៊ែរថ្មី និងអនុប្រធានក្រុមហ៊ុន Pacific Construction international Group និងកីឡាករកីឡាការិនី ទទួលជ័យលាភីមេដាយមាស<br>- ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា បានជួបសវនាការទ្វេភាគីជាមួយគណៈប្រតិភូវៀតណាម | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងសវនាការចំនួន០៥លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចចំនួន២៥លើក<br>- បានរៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាកេសជ្ជៈ និងផ្គត់ផ្គង់សម្ភារៈអនាម័យក្នុងពិធីផ្សេងៗចំនួន០៩លើក ស្មើនឹង១៧៧នាក់ |

| | |
|---|---|
| - ឯកឧត្តមអនុប្រធានទី២ ព្រឹទ្ធសភា បានជួបសំណេះសំណាលជាមួយអគ្គនាយករង ក្រុមហ៊ុនអគ្គិសនីស្ទឹងឫស្សីជ្រុំ ដើម្បីសិក្សាឈ្វេងយល់អំពីដំណើរការនៃការផលិតថាមពល និងការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅខេត្តកោះកុង<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតឡាវ តំណាងស្ថានទូតវៀតណាម ទីប្រឹក្សាអមស្ថានទូតព្រះរាជាណាចក្រថៃ អគ្គរដ្ឋអាជ្ញាអមតុលាការគណនេយ្យ ប្រធានសហព័ន្ធនារីអ៊ុយក្រែន និងអ្នកស្ម័គ្រចិត្តនៅការិយាល័យហ្វ្រង់កូហ្វូនីព្រឹទ្ធសភា ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ។ | - បានថតចម្លងឯកសារចំនួន៨០ច្បាប់ អស់ក្រដាសចំនួន៦៤២សន្លឹក<br>- បានផ្ដល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៦៨នាក់ ស្មើនឹង៣៥លើក<br>- បានធ្វើកំណត់បង្ហាញចំនួន០២លើក<br>- ធ្វើលិខិតទៅក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំជំនួយស្មារតីទំនាក់ទំនងទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦នាក់ ស្មើនឹង០២ច្បាប់<br>- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១១លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៥២នាក់ ស្មើនឹង០២លើក<br>- អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយរដ្ឋលេខាធិការក្រសួងមហាផ្ទៃវៀតណាម<br>- បានទំនាក់ទំនងជាមួយសភាសហព័ន្ធវ៉ាល់ឡូនី-ព្រុចសែល សមាគមបេសកកម្មសិក្សាអាស៊ី មន្ត្រីរបស់(IPU) ក្រសួង ស្ថាប័ន និងបណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅ ព្រឹត្តិបត្រ |

| | |
|---|---|
| | សម្រួលដល់កិច្ចការអន្តរជាតិ និងដំណើរទស្សនកិច្ច សិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| | + បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៤៧ច្បាប់ ។<br>+ការងារគ្រប់គ្រងបុគ្គលិកៈ<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៥៥ច្បាប់<br>- បានទទួលព្រះរាជក្រឹត្យផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងស្នើបន្ថែមទៅប្រមុខរាជរដ្ឋាភិបាល<br>- បានបញ្ចប់ការរៀបចំតម្លើងប្រាក់បំណាច់មុខងារមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំលេខាធិការដ្ឋានក្រមសីលធម៌ គណៈកម្មការក្រមសីលធម៌ ការពិចារណារៀបចំយន្តការនានា របស់ព្រឹទ្ធសភា នីតិកាលទី៤<br>- កិច្ចប្រជុំរួមជាមួយរដ្ឋសភាស្តីពី ការរៀបចំក្រមសីលធម៌សភាសម្រាប់តំណាងរាស្ត្រ និងកម្មវិធីរៀបចំសិក្ខាសាលារួមគ្នាអំពីការរៀនភាសាបារាំង<br>- ចាត់ចែងការបោះពុម្ពសៀវភៅជាភាសាបារាំងស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភា និងអគ្គលេខា- |

| | |
|---|---|
| | ធិការដ្ឋានព្រឹទ្ធសភា<br>- ចាត់ចែងការប្រជុំក្រុមប្រឹក្សាភិបាលវិទ្យាស្ថានសភាកម្ពុជា(PIC) ដើម្បីពិនិត្យវាយតម្លៃលទ្ធផលការងារឆ្នាំ២០១៧ និងផែនការឆ្នាំ២០១៨ ។<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេសសរុបចំនួន០១វគ្គ មានសិក្ខាកាមចូលរួមចំនួន០១នាក់ សិក្ខាសាលាក្នុងប្រទេសចំនួន០២លើក មានសិក្ខាកាមចូលរួមសរុបចំនួន០២នាក់ ។<br>+ចាត់ចែងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :<br>- ប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌនិងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងតារាងប្រាក់ឧបត្ថម្ភចូលឆ្នាំបន្ថែម ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន១៦សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៦២សំណើ សម្រាប់ |

| | |
|---|---|
| | កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន១២លើក មានអ្នកចូលរួមចំនួន៥២០នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣២៣លើក<br>- បានថតចម្លងឯកសារចំនួន៧,២៣៣ច្បាប់ និង បង់ក្រងសៀវភៅចំនួន០៩ក្បាល អស់ក្រដាស ចំនួន២៦,២៣២សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និង រាជធានីភ្នំពេញចំនួន៦២នាក់ ស្មើនឹង២៣លើកៗ<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់:<br>- រៀបចំគម្រោងស្នើសុំជំនួយពីប្រទេសជាមិត្ត សម្រាប់នីតិកាលទី២<br>- បន្តសាងសង់អគារថ្មី០១ខ្នងសម្រាប់ជាការិយាល័យធ្វើការបណ្តោះអាសន្ន និងសាងសង់ឃ្លាំងថ្មី នៅខាងក្រោយអគារ E<br>- បានជួសជុលអគារសមាជិកព្រឹទ្ធសភា (DEF) និងការបំពាក់សម្ភារៈបរិក្ខារ សម្រាប់នីតិកាលថ្មី<br>- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេ- |

ឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារៈ សារពើភ័ណ្ឌ និងប្រគល់សម្ភារៈសរុបចំនួន ៤១៩គ្រឿង

- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា ឲ្យមានសោភ័ណភាពល្អ
- រៀបចំបំពាក់អំពូលប្រើដោយថាមពលព្រះអាទិត្យ ក្នុងបរិវេណព្រឹទ្ធសភា
- បានតាំងពិព័រណ៌រូបភាព និងធ្វើហ្វុងអក្សរចំនួន ០៧លើក
- រៀបចំតបណ្ដាញខ្សែកាបអុបទិកសម្រាប់Live វីដេអូ ពល់សកម្មភាពក្នុងកិច្ចប្រជុំសំខាន់ៗ ពីសាលប្រជុំពេញអង្គទៅសាលបណ្ណាល័យ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកសារព័ត៌មានផ្ដិតយករូបភាព និងសម្លេងបានច្បាស់
- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន៩០គ្រឿង ។ បានUpload សេចក្ដីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្ដី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១៥៦ ចំណងជើង ។

+ការងារផ្សេងៗ:

- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតវីដេអូ សម្រាប់បង្ហោះលើ Alert News ចំនួន១៤៨ប្រធានបទ
- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុង

| | |
|---|---|
| | កម្មវិធីផ្សេងៗចំនួន២៦លើក<br>- បានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ ដាក់លេខកូដ និងបញ្ជូនសៀវភៅដាក់នៅសាលអាន ព្រមទាំងជួសជុលឯកសារសៀវភៅចាស់ៗសរុបចំនួន១៣៧ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម E-Library បណ្ដាញ Facebook សរុបចំនួន៦,៣១៧ក្បាល ។ |

**II.ទិសដៅការងារខែឧសភា ឆ្នាំ២០១៨**

-ដំណើរការរៀបចំយន្តការនានានៃនីតិកាលទី៤ ព្រឹទ្ធសភា ព្រមទាំងការផ្គត់ផ្គង់របប និងឧបករណ៍ចាំបាច់ ។

**១.មុខងារនីតិកម្ម**:

-ត្រៀមបើកសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ដើម្បីរៀបចំគណៈកម្មការនានា និងយន្តការសំខាន់ៗរបស់ព្រឹទ្ធសភា នីតិកាលទី៤ ព្រមទាំងគណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភាថ្មី ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមរៀបចំសិក្ខាសាលាស្តីពី កម្មវិធីផ្តល់ព័ត៌មានបឋមសម្រាប់សមាជិក សមាជិកាព្រឹទ្ធសភា នីតិកាលទី៤ ស្តីពី តួនាទី ភារកិច្ច សមត្ថកិច្ច និងយន្តការទាំងឡាយរបស់ព្រឹទ្ធសភា

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមផ្តល់ព័ត៌មានទៅស្ថានទូតបរទេស និងកម្ពុជាអំពីការប្រែប្រួលក្នុងនីតិកាលទី៤ ព្រឹទ្ធសភា

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-តាមដានគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

-ត្រៀមអនុវត្តន៍កម្មវិធីជាមួយ(APF)

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលនានាដែលចាត់ចែងដោយវិទ្យាស្ថានសភាកម្ពុជា(PIC)

-ការអនុវត្ត (MOU)សហប្រតិបត្តិការជាមួយព្រឹទ្ធសភាឥណ្ឌា និងប៉ាគីស្ថាន ដើម្បីឈានទៅបង្កើតអគ្គនាយកដ្ឋានខាងការស្រាវជ្រាវ ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-ត្រៀមកសាងអគារធ្វើការបណ្តោះអាសន្ន០១ខ្នង ឃ្លាំង០១ខ្នង ព្រមទាំងបំពាក់សម្ភារៈបរិក្ខារថ្មី និងបំពាក់អំពូលពន្លឺដោយប្រើថាមពលព្រះអាទិត្យ

-បន្តរៀបចំជួសជុលអគារការិយាល័យសមាជិកព្រឹទ្ធសភា

-ការងារតាមដានការសុំជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមមានការកសាងអគារសាលប្រជុំពេញអង្គថ្មី សម្ភារៈបរិក្ខារអេឡិចត្រូនិច និងរថយន្ត

-ត្រៀមផ្តល់ឯកសារ និងលិខិតបទដ្ឋានគតិយុត្តិនានា ជូនដល់សមាជិកព្រឹទ្ធសភានីតិកាល៤

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការ

បណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ទំនាក់ទំនងជាថ្មីជាមួយភាគីវៀតណាម ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត ឆ្នាំ២០១៨

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ការត្រៀមរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល (២០១៩-២០២១) និងគម្រោងថវិកាឆ្នាំ២០១៩

-ការត្រៀមរៀបចំថវិកាកម្មវិធីឆ្នាំ២០១៩ ។

**III.សេចក្តីសន្និដ្ឋាន**

ខែមេសានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំពិធីសូត្រមន្ត និងជប់លៀងអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងការបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៤ និងសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ បានចូលដល់ការអនុវត្តជាក់ស្តែងក្នុងខែមេសា ឆ្នាំ២០១៨នេះ ដោយមានវិសាលភាពគ្របដណ្តប់ និងអត្ថន័យនយោបាយដ៏ជ្រាលជ្រៅក្នុងដំណើរទៅមុខរបស់ព្រឹទ្ធសភា ដែលត្រូវចាប់ផ្តើមទំព័រថ្មីសម្រាប់៦ឆ្នាំទៅមុខទៀត ។ ជាពិសេសការត្រៀមកន្ទែងធ្វើការហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថាន និងការបំពាក់សម្ភារៈការិយាល័យថ្មី ជូនសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលថ្មី ។ ចំពោះការអភិវឌ្ឍស្ថាប័ននៅតែបន្ត និងបង្កើនសមត្ថភាពស្រាវជ្រាវ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារឲ្យបានជាអតិបរមា ព្រមទាំងសមត្ថភាពភាសាបរទេស និងជំនាញផ្សេងៗទៀតកាន់តែល្អ និងរហ័សជាងមុន ។ ជំនាញឯកទេស ជំនាញស្រាវជ្រាវ និងភាសាបរទេសកាន់តែមានតម្រូវការធំជាងមុនដែលត្រូវខិតខំឆ្លើយតបឲ្យបានល្អប្រសើរ ។ ចំណែកការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានបន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើឲ្យព្រឹទ្ធសភានីតិកាលថ្មីដំណើរការកាន់តែល្អប្រសើរ ។

ព្រឹទ្ធសភាត្រូវត្រៀមដើរតួនាទីជំនួសរដ្ឋសភាកម្ពុជាក្នុងវេទិកា APF នៅទីក្រុងQuebec នៃប្រទេសកាណាដា និងវេទិកា AIPA នៅសាធារណរដ្ឋសិង្ហបុរី និងទីក្រុងហ្សឺណែវ នៃប្រទេសស្វីស ព្រមទាំងរួមគ្នារៀបចំវេទិកា APPF ខែមករា ឆ្នាំ២០១៩ នៅខេត្តសៀមរាប ។

សិក្ខាសាលា APF ក្នុងខែឧសភា អំពីកម្មវិធី Noria និងសិក្ខាសាលាផ្តល់ព័ត៌មានបឋម ជូនសមាជិកព្រឹទ្ធសភាគឺជាជំហានចាប់ផ្តើមមួយដ៏សំខាន់ ។

ថ្ងៃ ទេស្សារ០៩ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ